**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ......៦៣៦.........ក. ស. ភ.

ថ្ងៃអង្គារ ៥រោច ខែផល្គុន ឆ្នាំមមី អដ្ឋស័ក ព.ស២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មីនា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមពិគ្រោះថ្លៃ
## លើការផ្គត់ផ្គង់ចង្កៀងសញ្ញាចំនួន២០ គ្រឿង និងសម្ភារសម្រាប់ជួសជុលថៃទាំពោង និងបង្គោលសញ្ញាផ្លូវនាវាចរណ៍តាមដងទន្លេសាប ទន្លេមេគង្គលើ និងទន្លេមេគង្គក្រោម
## (ភ្នំពេញ-ក្អមសំណរ)

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា កំពង់ផែស្វយ័តភ្នំពេញនឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈលើការផ្គត់ផ្គង់ចង្កៀងសញ្ញាចំនួន២០ គ្រឿង និងសម្ភារសម្រាប់ជួសជុលថៃទាំពោង និងបង្គោលសញ្ញាផ្លូវនាវាចរណ៍តាមដងទន្លេសាប ទន្លេមេគង្គលើ និងទន្លេមេគង្គក្រោម (ភ្នំពេញ-ក្អមសំណរ) ។

កំពង់ផែស្វយ័តភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម កំពង់ផែស្វយ័តភ្នំពេញ ដែលមានអាសយដ្ឋានអគារលេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញចាប់ពីថ្ងៃទី...១០.......ខែមីនា.....ឆ្នាំ២០២៦ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទំនាក់ទំនងលេខ ០១០ ៤៤៤ ៦៩៥/០១០ ៤៤៤ ៦៣៤)។

កាលបរិច្ឆេទឈប់ទទួលពាក្យសំណើពិគ្រោះថ្លៃនៅវេលាម៉ោង១៤...៣០.នាទី ថ្ងៃទី២៥..ខែមីនា... ឆ្នាំ២០២៦។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង** ១៤:៣០...នាទី ថ្ងៃទី.២៥....ខែមីនា...ឆ្នាំ២០២៦។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ជួន សុខេម**

ទីស្នាក់ការកណ្តាល: #៦៤៩ គិតវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទ (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh